# គោលនយោបាយសមាជិកភាព
# របស់ក្រុមប្រឹក្សាសកម្មភាពជនពិការ

## សេចក្តីផ្តើម

ក្រុមប្រឹក្សាសកម្មភាពជនពិការ (កសជ) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៧ ជាយន្តការសម្របសម្រួល និងផ្តល់ប្រឹក្សាថ្នាក់ជាតិលើបញ្ហាពិការភាព ហើយត្រូវបានចែងក្នុង ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ដែលបានឡាយព្រះហស្តលេខាដោយ ព្រះបាទនរោត្តម សីហមុនីព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ។ មាត្រាទី៦ នៃច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធជនពិការបានចែងថាក្រុមប្រឹក្សាសកម្មភាពជនពិការមានភារកិច្ចដូចខាងក្រោម៖

1. ផ្តល់ការពិគ្រោះយោបល់ជំនាញលើបញ្ហាពិការភាពនិងស្តារលទ្ធភាពពលកម្ម
2. ជួយក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធ ក្នុងការរៀបចំគោលនយោបាយ ផែនការជាតិ និងយុទ្ធសាស្ត្រដែលមានការពាក់ព័ន្ធទៅនឹងវិស័យពិការភាពនិងស្តារលទ្ធភាពពលកម្ម
3. ជំរុញការអនុវត្តគោលនយោបាយច្បាប់និងបទបញ្ញាផ្សេងៗដែលពាក់ព័ន្ធទៅនឹងវិស័យពិការភាពនិងស្តារលទ្ធភាពពលកម្ម
4. លើកសំណើកែសម្រួល បំពេញបន្ថែម ធ្វើវិសោធនកម្ម គោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនិងបញ្ហាពិការភាព
5. តាមដាន វាយតម្លៃ ការអនុវត្តគោលនយោបាយ ផែនការជាតិ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនិងបញ្ហាពិការភាព
6. ទំនាក់ទំនងជាមួយសហគមន៍ជាតិ អន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ កៀរគរប្រភពធនធានទាំងក្នុងនិងក្រៅប្រទេស ។

## គោលបំណងនៃសមាជិកភាពរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ

មានអង្គការ ស្ថាប័ននិងបុគ្គលជាច្រើនដែលប្តេជ្ញា យកចិត្តទុកដាក់គាំទ្រជនងាយរងគ្រោះនៅតាមសហគមន៍ជាពិសេសជនពិការ ទៅតាមសេវាដែលបានកំណត់ដោយឡែកពីគ្នា ។ អ្នកខ្លះផ្តោតទៅលើក្រុមគោលដៅជារួម និងអ្នកខ្លះផ្តោតតែទៅលើក្រុមគោលដៅជាក់លាក់ដូច ជាកុមារពិការ ស្ត្រីពិការជាដើម ។ល។ ទោះបីជាយ៉ាងណាក៏ដោយក៏មានការកត់សំគាល់ឃើញថា ការផ្តល់សេវាកម្មទាំងនោះមានដូចជាវិស័យសុខភាព អប់រំ ស្តារលទ្ធភាពពលកម្ម ជីវភាពរស់នៅ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ល។ នៅតាមមជ្ឈមណ្ឌលនានា និងនៅតាមសហគមន៍ផ្ទាល់នឹងកាន់តែមានប្រសិទ្ធិភាពជាមួយនិងអ្នកទទួលផលប្រសិនបើមានអ្នក/ការសម្របសម្រួល ។ បើសេវាកម្មទាំងឡាយគ្រាន់តែត្រូវបានផ្តល់ ជូន ផ្ទាល់ពី

ប្រតិបត្តិករទៅឲ្យអ្នកទទួលផលហើយប្រតិបត្តិករទាំងនោះមិនមានឱកាសជួបពិភាក្សា រៀនសូត្រនិងចែករំលែកគ្នាទៅវិញទៅមកទេ និងមានផល ប៉ះពាល់ទៅដល់ប្រសិទ្ធិភាពនិងគុណភាពនៃសេវាកម្មទាំងនោះជាមិនខាន ព្រោះថាប្រតិបត្តិករទាំង អស់មានទស្សនវិស័យនិងបេសកកម្មនិងកំណត់ពីប្រភេទសេវាកម្មផ្សេងៗគ្នា កំប៉ុន្តែនៅក្នុងទិសដៅរួមតែ មួយគឺបង្កើនគុណភាពជិវិតរស់នៅរបស់ជនពិការ ។ ហេតុដូចនេះហើយវាពិតប្រាកដណាស់ថាវាត្រូវតែមានការសម្របសម្រួលពីអ្នកណាមួយសម្រាប់ទាំងអស់គ្នាទៅតាមប្រភេទប្រតិបត្តិករនិងសេវាកម្មទាំងនោះ ។

សមាជិកភាពរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ (កសជ) ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើ និងធ្វើជាតំណាង សំឡេងរួមមួយតាមរយៈការពិគ្រោះយោបល់យ៉ាងទូលំទូលាយនៅក្នុងវិស័យដើម្បីបញ្ចុះបញ្ចូល ជាមួយក្រសួងពាក់ព័ន្ធន និងដៃគូពាក់ព័ន្ធនានា ដើម្បីលើកសំណើពិនិត្យឡើងវិញបំពេញបន្ថែម និងធ្វើវិសោធនកម្មច្បាប់ បទដ្ឋាន គោលការណ៍ និងគោលនយោបាយនានាក្នុងការបញ្ចូលពិការភាព ក៏ដូចជាការត្រួតពិនិត្យតាមដាន និងវាយតម្លៃក្របខ័ណ្ឌច្បាប់ទាំងនោះ ។ ជាមួយគ្នានេះដែរ ក.ស.ជ ដើរតួជាកន្លែងដែលសមាជិក និងក្រសួងជួបគ្នា និងចែករំលែកពីព័ត៌មាន ការអនុវត្តល្អ បញ្ហាប្រឈម មេរៀនពិសោធន៍ ដើម្បីបង្កើតអនុសាសន៍ជាក់លាក់មួយចំនួនដាក់ជូនដល់ក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធនានា និងដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងនូវគុណភាពនៃសេវាកម្មដែលខ្លួនកំពុងផ្តល់ជូនក្រុមគោលដៅ។

## អ្នកណាអាចក្លាយជាសមាជិករបស់ក.ស.ជ

ស្ថាប័ន អង្គការជាតិនិងអន្តរជាតិ និងឯកត្តបុគ្គលមកពីវិស័យពិការភាព និងពីវិស័យមិនមែនពិការភាព ដែលមាន គោលបំណង និងទស្សនៈវិស័យក្នុងការអភិវឌ្ឍន៍វិស័យពិការភាព អាចដាក់ពាក្យ ជាសមាជិករបស់ ក.ស.ជ បាន ។

### ក.សម្រាប់អង្គការជាតិនិងឯកត្តបុគ្គល

ថ្លៃសមាជិកភាពប្រចាំឆ្នាំគឺ0.0៥% នៃថវិកាប្រចាំឆ្នាំសរុបរបស់អង្គភាព។ ឧទាហរណ៍៖ ថវិកាប្រចាំឆ្នាំគឺ ១.000.000ដុល្លាអាមេរិក នោះថ្លៃសមាជិកភាពគឺ ៥00ដុល្លាអាមេរិកក្នុងមួយឆ្នាំ ។ សម្រាប់ករណីឯកត្តបុគ្គលតម្លៃសមាជិកភាពប្រចាំឆ្នាំចាប់ពី ២0 ដុល្លាអាមេរិកឡើងទៅ ។

### ខ.សម្រាប់អង្គការអន្តរជាតិ

ថ្លៃសមាជិកភាពប្រចាំឆ្នាំ គឺ 0.១% នៃថវិកាប្រចាំឆ្នាំសរុបរបស់អង្គភាព ។ ឧទាហរណ៍៖ ថវិកាប្រចាំឆ្នាំគឺ ១.000.000ដុល្លាអាមេរិក នោះថ្លៃសមាជិកភាពគឺ ១000 ដុល្លាអាមេរិក និងខ្ពស់បំផុត ២000 ដុល្លាអាមេរិកក្នុងមួយឆ្នាំ ទោះបីជាថវិកាប្រចាំឆ្នាំរបស់អង្គការច្រើនជាង ចំនួនឧទាហរណ៍ខាងលើក៏ដោយ។

## តើផលប្រយោជន៍អ្វីដែលសមាជិកទទួលបាន?

គ្រប់អង្គការ ស្ថាប័ន និងឯកត្តបុគ្គលទាំងអស់ដែលបានចុះឈ្មោះជាសមាជិកក្រុមប្រឹក្សាសកម្មភាពជនពិការនិងទទួលបានផលប្រយោជន៍ដូចខាងក្រោម:

- ទទួលការគាំទ្រការងារសម្របសម្រួល ការងារបណ្តាញ ការងាររដ្ឋបាលសមស្រប និងជំនួយបច្ចេកទេសពី ក.ស.ជ
- ទទួលជំនួយបច្ចេកទេស និងការគាំទ្រសមស្របក្នុងការធ្វើយុទ្ធសាស្ត្រ ផែនការគម្រោង ការធ្វើសំណើថវិកាគម្រោង
- ជំនួយក្នុងការសរសេរសំណើថវិការួមរវាងអង្គការសមាជិកនិង កសជ ដើម្បីដាក់ជូនទៅម្ចាស់ជំនួយដែលមានសក្តានុពល
- ទទួលបានលិខិតគាំទ្រដើម្បីភ្ជាប់ជាមួយពេលដាក់សំណើគម្រោង ទៅម្ចាស់ជំនួយដែលមានសក្តានុពលលិខិតនោះអាចនិងចុះហត្ថលេខាដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទាបើមានការស្នើសុំ ។
- ទទួលបានព័ត៌មាន/ទិន្នន័យទាក់ទងបញ្ហាពិការភាព និងអាចលើកកិត្តិយស អង្គភាព ដោយរក្សាទុកនូវព័ត៌មាននៅមជ្ឈមណ្ឌលឯកសារពិការភាពកម្ពុជានៅក្នុងលេខាធិការដ្ឋាន ក.ស.ជ និងដាក់ក្នុងគេហទំព័ររបស់ក.ស.ជ
- ទទួលបានព័ត៌មានតាមរយៈព្រឹត្តិប័ត្រអេឡិចត្រូនិច ព្រឹត្តិប័ត្ត របាយការណ៍ ក្រដាសផ្ទត់ដំណឹងជ្រើសរើសបុគ្គលិក និងការជួយចែកផ្សាយផ្សេងៗ
- អាចទទួលបានកាតព្វកិច្ចថ្នាក់ជាតិ និងអន្តរជាតិលើវិស័យពិការភាព
- ផ្តល់នូវព័ត៌មានត្រឡប់បែបស្ថាបនា ពីបញ្ហាដែលពាក់ព័ន្ធទៅនឹងសកម្មភាពនានា និង ប្រតិ បត្តិការរបស់ ក.ស.ជ ដើម្បីការរីកចំរើននាពេលអនាគត
- មានសិទ្ធិក្នុងការសម្រេចចិត្តនៅក្នុងគណៈកម្មការ និងក្រុមការងារ លើបញ្ហា ផ្សេងៗតាមរយៈអនុវិស័យដែលខ្លួនជាប់ពាក់ព័ន្ធ
- មានឱកាសទទួលបានការកសាងសមត្ថភាពនិងបង្កើនការទំនាក់ទំនងតាមរយៈវគ្គបណ្តុះបណ្តាល/អាហាររូបករណ៍/សន្និសីទ/ទស្សនកិច្ចសិក្សា/កិច្ចប្រជុំ ។ល។ ក្នុងស្រុក និងអន្តរជាតិ ដោយ ក.ស.ជ និង/ឬដៃគូ
- ទទួលបានចន្លោះទំនេរក្នុងគេហទំព័រ ក.ស.ជ ដើម្បីភ្ជាប់ទៅកាន់គេហទំព័រអង្គការ/បុគ្គលជាសមាជិក ដែលអាចផ្តល់ផលប្រយោជន៍ដល់អង្គការសមាជិកភ្ជាប់ទៅកាន់អង្គការ/ស្ថាប័នដែលពាក់ព័ន្ធ ដែលជាសមាជិកទាំងក្នុង និងក្រៅប្រទេស
- ទទួលការសរសើរអំពីកក្រសួងនៃរាជរដ្ឋាភិបាលកម្ពុជា ដែលពាក់ព័ន្ធ ដោយសារសម្រេចបាននូវស្នាដៃជាក់លាក់ណាមួយ តាមរយៈកិច្ចសម្របសម្រួលរបស់ក.ស.ជ

- សម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ ដើម្បីចុះហត្ថលេខាអនុស្សារៈយោគយល់ នៅគ្រប់កំរិតជាមួយសមាជិកនានា ប្រសិនបើជាតម្រូវការរបស់សមាជិក
- ពិគ្រោះយោបល់ក្នុងការចុះឈ្មោះកម្មវិធីថ្មីរបស់សមាជិកជាមួយក្រសួងពាក់ព័ន្ធ
- សម្របសម្រួលដោះស្រាយរាល់បញ្ហារបស់សមាជិកជុំវិញវិស័យពិការភាព
- អន្តរាគមន៍ដោយផ្ទាល់ទៅកាន់ករណីបុគ្គលរបស់ជនពិការដែលលើពីសមត្ថភាពរបស់សមាជិក
- សម្របសម្រួលអញ្ជើញភ្ញៀវកិត្តិយសចូលរួមជាអធិបតីក្នុងកម្មវិធីនានាដែលរៀបចំឡើងដោយសមាជិករបស់ខ្លួន
- ទទួលថវិកាគាំទ្រអំពីដៃគូអភិវឌ្ឍន៍ប្រកបដោយសក្តានុពលផ្សេងៗតាមរយៈការចង្អុលបង្ហាញពីក.ស.ជ
- ទទួលព័ត៌មាន /សេចក្តីជូនដំណឹងរកការងារថ្មីរបស់សមាជិកទាំងអស់តាមរយៈក.ស.ជ
- ទទួលបានការសម្របសម្រួលក្នុងការចង់ជួបប្រជុំជាមួយថ្នាក់ដឹកនាំនៅតាមក្រសួងពាក់ព័ន្ធ
- សហការរៀបចំទិវាផ្សេងៗជាមួយសមាជិកបើមានការស្នើសុំ
- ជួយស្វែងរកអ្នកស្ម័គ្រចិត្ត និងកម្មសិក្សាការីជាជនជាតិកម្ពុជា ឬបរទេស ជូនអង្គការសមាជិកទៅតាមជំនាញដែលត្រូវការបើមានការស្នើសុំជាលាយលក្ខអក្សរ ។

## តើត្រូវចុះឈ្មោះដូចម្តេចដើម្បីក្លាយជាសមាជិក?

គ្រប់អង្គការ/ស្ថាប័ន និងបុគ្គលនានា ដែលមានចំណាប់អារម្មណ៍ក្លាយជាសមាជិករបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ អាចៈ

- បំពេញទំរង់ពាក្យសុំដែលភ្ជាប់មកជាមួយខាងក្រោយ ដោយច្បាប់ដើម ឬច្បាប់ចម្លង
- ផ្ញើមកកាន់លេខាធិការដ្ឋាននូវទម្រង់ដែលបំពេញរួច តាមរយៈអ៊ីម៉ែល ឬតាមប្រអប់សំបុត្រ
- បង់ថ្លៃសមាជិកភាពដោយប្រាក់សុទ្ធ ឬមូលប្បទានបត្រ មកកាន់លេខាធិការដ្ឋាន ឬដោយផ្ទេរចូលគណនីធនាគាររបស់ក.ស.ជ ដោយមានការជូនដំណឹងមកកាន់លេខាធិការដ្ឋាន។
- ថវិកាប្រចាំឆ្នាំអង្គភាពរបស់សមាជិកមិនតម្រូវឲ្យបង្ហាញថាព្រោះជាផ្ទៃក្នុងរបស់ខ្លួន

## តើថវិកាសមាជិកភាពប្រើប្រាស់សម្រាប់ធ្វើអ្វី?

- ថវិកាពីសមាជិកភាពត្រូវបានប្រើប្រាស់ក្នុងការគាំទ្រសកម្មភាពនៃគណៈកម្មការ អនុគណៈកម្មការ ក្រុមការងារ វេទិកា និងកិច្ចប្រជុំ ដែលបង្កើតឡើងនិងសម្របសម្រួលតាមរយៈអនុវិស័យ ដែលលោក លោកស្រីពាក់ព័ន្ធ។
- ថិវិកាពីសមាជិកភាពត្រូវបានប្រើប្រាស់សំរាប់ដោះស្រាយកិច្ចការបួតម្រូវការចាំបាច់នៅក្នុងលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ។

---

ព័ត៌មានលំអិត សូមទាក់ទងៈ
លេខាធិការដ្ឋាន ក.ស.ជ
អគារលេខ៧៨៨ មហាវិថីមុនីវង្ស ខណ្ឌចំការមន រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជាប្រអប់សំបុត្រ លេខ ១១៥
អ៊ីម៉ែលៈ dac@dac.org.kh / sambath@dac.org.kh
ទូរស័ព្ទៈ (855) 17 555 653/(855) 12 948 020 គេហទំព័រៈ www.dac.org.kh

## ពាក្យសុំចូលជាសមាជិក
## របស់ក្រុមប្រឹក្សាសកម្មភាពជនពិការ (ក.ស.ជ)

ក្រុមប្រឹក្សាសកម្មភាពជនពិការ (កសជ)ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៧ ជាយន្តការសម្របសម្រួល និងផ្តល់ប្រឹក្សាថ្នាក់ជាតិលើផ្នែកពិការភាព ហើយត្រូវបានចែងក្នុងច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការដែលបានឡាយព្រះហស្តលេខាដោយ ព្រះបាទនរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩។

ផ្នែកទី១៖

ឈ្មោះអង្គភាព: (ភាសាខ្មែរ)______________________________
(ភាសាអង់គ្លេស)______________________________

ឈ្មោះអ្នកទំនាក់ទំនង: ______________________________

អាស័យដ្ឋាន: ______________________________

ទូរស័ព្ទការិយាល័យ: ____________________ទូរស័ព្ទចល័ត:______________

ទូរសារ: ____________________អ៊ី ម៉ែល:______________

វិបសាយ: ______________________________

ព័ត៌មានអង្គការ: ______________________________

ផ្នែកទី២៖

ប្រភេទអង្គភាព: □ អង្គការក្នុងស្រុក □ អង្គការអន្តរជាតិ □ ក្រសួង □ឯកជន □ ផ្សេងៗ

បានចុះបញ្ជីនៅកម្ពុជា: □ បាទ/ចាស □ ទេ

ចុះអនុស្សារណៈជាមួយ: ____________________ថ្ងៃខែឆ្នាំចុងក្រោយ______________

កាលបរិច្ឆេទចុះបញ្ជី: ថ្ងៃ__ __/ខែ__ __/ឆ្នាំ__ __ __ __

ផ្នែកទី៣៖

បង់សមាជិកភាពសម្រាប់ឆ្នាំ: □ 2011 □ 2012 □ 2013 □ 2014 □ 2015

តម្លៃសមាជិកភាព(ជាដុល្លារអាមេរិក) :______________________________

ផ្នែកទី៤៖

ទស្សនៈវិជ្ជា (ចក្ខុវិស័យ, បេសកកម្ម និងពាក្យស្លោក):

ក.ចក្ខុវិស័យ:

______________________________

______________________________

ខ.បេសកកម្ម:

______________________________

______________________________

ផ្នែកទី៥៖

កម្មវិធី/គម្រោងចំបងៗ:

1. ____________________ 3.____________________
2. ____________________ 4.____________________

ផ្នែកទី៦៖

ទីកន្លែងអនុវត្តន៍កម្មវិធី/គម្រោង:

1. ____________________ 3.____________________
2. ____________________ 4.____________________